# អាឡោះអាល័យ

ពិព័រណ៍រូបថតប្រើហ្វីល

ប្រកាសទទួលពាក្យ

កិច្ចសហការរវាងហាងកាហ្វេចាវ៉ា និងស្ទូឌីយ៉ូ RUUB
កាលបរិច្ឆេទនៃការតាំងពិព័រណ៏៖ ថ្ងៃទី៧ ខែតុលា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣
ទីតាំង៖ ហាងកាហ្វេចាវ៉ាសាខាទួលគោក និងទួលទំពូង
មូលបទ៖ អាឡោះអាល័យ
០៩៣ ៦០១ ២៧២

សូមយករូបថតចាស់ៗរបស់អ្នកចេញមក មិនថានោះជារូបថតគ្រួសារ រូបមួយកំណាត់ខ្លួន និងរូបថតនានាដែលផ្តិតជាប់នូវពេលវេលាដ៏អស្ចារ្យ!

ហាងកាហ្វេចាវ៉ា និងស្ទូឌីយ៉ូ RUUB សូមអញ្ជើញអ្នកថតរូប (ទាំងអាជីព និងអ្នកថតជាការកម្សាន្ត) ផ្ញើរូបថតប្រើហ្វីលដែលបានថតក្នុងប្រទេសកម្ពុជាដែលត្រូវនឹងមូលបទ «អាឡោះអាល័យ»។ យើងនឹងជ្រើសរើសរូបថតចំនួន២០ សន្លឹក យកមកផ្តិត រួចដាក់បញ្ចូលក្នុងពិព័រណ៍រយៈពេលបីខែ នៅហាងកាហ្វេចាវ៉ាទាំងពីរសាខា គឺនៅទួលគោក និងទួលទំពូង។

- ពិព័រណ៍នេះនឹងជ្រើសរើសរូប ១ សន្លឹក ពីបេក្ខជនម្នាក់ ហើយរូបនោះនឹងត្រូវផ្តិតចេញ២ សន្លឹក ដើម្បីដាក់តាំងបង្ហាញនៅទីតាំងពិព័រណ៍ទាំងពីរ។
- រូបថតចំនួន២០ សន្លឹក នឹងត្រូវសម្រេចជ្រើសរើសដោយហាងកាហ្វេចាវ៉ា និងស្ទូឌីយ៉ូ RUUB ។
- យើងនឹងរៀបចំកម្មវិធីបើក ហើយព័ត៌មានលម្អិតនឹងប្រកាសជូននៅពេលក្រោយ។
- បន្ថែមពីនេះ យើងនឹងផ្សព្វផ្សាយរូបថតដែលបានជ្រើសរើសនៅលើបណ្តាញសង្គម និងវេបសាយដោយផ្តល់ក្រេឌីតទៅកាន់អ្នកថតរូប។ យើងអាចនឹងផ្សព្វផ្សាយរូបភាពដែលបានជ្រើសរើសមួយចំនួនតាមរយៈអនឡាញ ដែលរូបទាំងនោះមិនមានតាំងនៅទីតាំងតាំងពិព័រណ៍ទេ។
- សម្រាប់ការបញ្ជូនរូបមកកាន់ពិព័រណ៍នេះ អ្នកត្រូវធានាថា អ្នកមានសិទ្ធិចែករំលែករូបភាពទាំងអស់នេះ ហើយអ្នកផ្តល់ការអនុញ្ញាតឱ្យពួកយើងផ្សព្វផ្សាយរូបភាពទាំងនេះតាមរយៈអនឡាញ និង/ឬសម្រាប់ការតាំងពិព័រណ៍។

## លក្ខខណ្ឌចូលរួម

សូមផ្ញើរូបថតផ្សេងៗដែលត្រូវនឹងមូលបទអាឡោះអាល័យ! អ្នកអាចបកស្រាយរូបភាព និងភាពអាឡោះអាល័យបែបណាក៏បាន តាមវិធីរបស់អ្នក!

រូបថតមានអនុភាពដ៏ខ្លាំងក្លា ក្នុងការផ្ដិតនូវអនុស្សាវរីយ៍ និងពេលវេលាសំខាន់ៗទាំងឡាយនៃជីវិតរបស់យើង និងប្រវត្តិសាស្ត្រ។ យើងប្រារព្ធអនុភាពនៃរូបថតទាំងអស់នេះ ក៏ដូចជាសោភ័ណភាពនៃរូបថតប្រើហ្វីល តាមរយៈការតាំងពិព័រណ៍ជាលក្ខណៈសហគមន៍។ យើងសូមស្វាគមន៍អ្នកដែលបញ្ជូនរូបថតប្រើហ្វីល ដែលបានថតក្នុងប្រទេសកម្ពុជា។ រូបថតលើប្រធានបទអ្វីក៏បាន! យើងចាប់អារម្មណ៍ទៅលើរូបថតដែលទាក់ទងនឹងនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ក៏ដូចជារូបថតផ្ទាល់ខ្លួនអ្នកផងដែរ។ រូបថតទាំងនោះ អាចរាប់ចាប់ពីសកម្មភាពប្រចាំថ្ងៃ ដូចជាការនេសាទ ឬការចម្អិនម្ហូបអាហារ ឬក៏កម្មវិធីគ្រួសារមួយចំនួន ដូចជាការរៀបអាពាហ៍ពិពាហ៍ និងជប់លៀង ឬក៏រូបមួយកំណាត់ខ្លួនថតនៅសួនច្បារក៏បាន។

- រូបថតត្រូវតែជារូបថតប្រើហ្វីល (រូបថតបែបឌីជីថលមិនអាចអនុញ្ញាតបានឡើយ)។
- រូបថតត្រូវតែជារូបដែលបានថតនៅប្រទេសកម្ពុជា ប៉ុន្តែអ្នកថតរូបអាចមានវ័យ ឬសញ្ជាតិណាក៏បាន។
- អ្នកអាចផ្ញើរូបថតដែលនរណាម្នាក់ទៀតជាអ្នកថតក៏បាន ប៉ុន្តែអ្នក**ត្រូវតែទទួលការអនុញ្ញាត**ពីម្ចាស់រូបដើម ឬពីក្រុមគ្រួសាររបស់ពួកគេ។
- អ្នកថតរូបម្នាក់ៗអាចផ្ញើរូបបានរហូតដល់១០ សន្លឹក ប៉ុន្តែសម្រាប់ការជ្រើសរើស យើងនឹងជ្រើសរើសរូបតែ១ សន្លឹក ប៉ុណ្ណោះ។
- រូបថតទាំងអស់ត្រូវតែអនុលោមតាមច្បាប់ និងស្តង់ដានៃវប្បធម៌កម្ពុជា ហើយយើងសូមរក្សាសិទ្ធិដើម្បីដកចេញរូបថតទាំងឡាយណាដែលយើងយល់ថាមិនសមរម្យ។

## តម្លៃត្រូវបង់

ការដាក់ពាក្យចូលរួម គឺមិនគិតថ្លៃទេ ប៉ុន្តែអ្នកថតរូបជាប់ជម្រើសនឹងត្រូវបង់ថ្លៃសម្រាប់ការស្កេន និងការផ្តិតរូប។ ដើម្បីធ្វើឱ្យគុណភាពរូបដាក់តាំងមានទម្រង់តែមួយ យើងនឹងមិនអនុញ្ញាតឱ្យអ្នកថតរូប ស្កេន ឬផ្តិតរូបសម្រាប់ការតាំងពិព័ណ៌នេះដោយខ្លួនឯងឡើយ។ សូមអរគុណចំពោះការយោគយល់របស់អ្នកទាំងអស់គ្នា!

- ស្កេន ៖ តម្លៃក្នុងហ្វីលមួយសន្លឹក ៦ដុល្លារ / ៣៥ម.ម ឬ៦.៥ដុល្លារ ទំហំមធ្យម (ធំជាង ៦x៧)
- ផ្តិតរូបថតដោយស្ទូឌីយ៉ូ RUUB៖ ទំហំ A4 តម្លៃ១០ ដុល្លារ ក្នុងមួយសន្លឹក x ២ = ២០ ដុល្លារ

## ពេលវេលា៖

ខែមិថុនា ប្រកាសទទួលពាក្យ

៣១ សីហា ថ្ងៃផុតកំណត់ទទួលពាក្យ

១១ កញ្ញា ការប្រកាសរូបថតដែលបានជ្រើសរើស ផ្ញើការទាក់ទងដើម្បីអញ្ជើញចូលរួមកម្មវិធីបើកពិព័រណ៍

៧ តុលា កម្មវិធីបើកពិព័រណ៍

## របៀបដាក់ពាក្យ

សូមផ្ញើព័ត៌មានខាងក្រោមទៅកាន់អ៊ីមែល hello@javacreativecafe.com

- ឈ្មោះ អាយុ និងទីលំនៅបច្ចុប្បន្ន
- អ៊ីមែល និងលេខទូរស័ព្ទ
- រូបថតនីមួយៗត្រូវបញ្ចូលនូវព័ត៌មានមួយចំនួនដូចជា៖ លេខ (១ ២ ៣ ។ល។), ចំណងជើង (ដាក់ក៏បាន), ឈ្មោះអ្នកថតរូប, ឆ្នាំដែលបានថត និងទីតាំងដែលបានថត។
- រូបថតស្កេន ជាមួយនឹងលេខដែលបានដាក់ ឈ្មោះរបស់អ្នកនៅក្នុងឈ្មោះឯកសារ ខ្នាត១៥០០ ភិចសែល ប្រភេទ jpeg (ទំហំប្រហែល១ មេហ្គាបៃ)

បញ្ជាក់៖ ឯកសាររូបថតស្កេនដែលបញ្ជូនមកអាចមានគុណភាពបែបណាក៏បាន ប៉ុន្តែរូបថតជម្រើសសម្រាប់ការតាំងពិព័រណ៍នឹងត្រូវស្កេនឡើងវិញក្នុងគុណភាពខ្ពស់ដើម្បីផ្តិតចេញជារូប។

## សំណួរដែលទទួលបានញឹកញាប់

តើនរណាអាចផ្ញើរូបថតមកបាន?

- នរណាក៏បានដែរ! ប៉ុន្តែរូបថតទាំងនោះត្រូវតែថតឡើងនៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់រូបថតប្រើហ្វីល។

Java

ចុះបើខ្ញុំមិនមែនជាអ្នកថតរូបនោះ?

- អត់បញ្ហា! អ្នកអាចបញ្ជូនរូបថតដែលអ្នកផ្សេងថតក៏បាន ប៉ុន្តែអ្នក**ត្រូវតែទទួលការអនុញ្ញាត**ពីអ្នកថតរូបដើម ឬពីក្រុមគ្រួសាររបស់ពួកគេជាមុនសិន។

តើខ្ញុំអាចបញ្ជូនរូបថតទាំងនោះដោយរបៀបណា?

- សូមផ្ញើរូបថតច្រើនបំផុតត្រឹម ១០ សន្លឹកទៅកាន់ hello@javacreativecafe.com ! សូមដាក់ឈ្មោះ អាយុ និងទីលំនៅបច្ចុប្បន្ន អ៊ីមែល និងលេខទូរស័ព្ទរបស់អ្នក។
- រូបថតនីមួយៗត្រូវបញ្ចូលនូវព័ត៌មានមួយចំនួនដូចជា៖ លេខ (១ ២ ៣ ។ល។), ចំណងជើង (ដាក់ក៏បាន), ឈ្មោះអ្នកថតរូប, ឆ្នាំដែលបានថត និងទីតាំងដែលបានថត។
- រូបថតស្កេន ជាមួយនឹងលេខដូចដែលបានដាក់ក្នុងឯកសារ ប្រភេទjpeg ខ្នាត១៥០០ ភិចសែល (ទំហំប្រហែល១ មេហ្គាបៃ)

តើរូបថតប្រភេទណាដែលខ្ញុំអាចផ្ញើទៅបាន?

- រូបថតអ្វីក៏បាន ប្រធានបទអ្វីក៏បាន អាចជារូបថតពណ៌ ឬរូបស-ខ្មៅ ឱ្យតែរូបនោះត្រូវបានថតឡើងជារូបថតដោយប្រើហ្វីល។

តើរូបថតគួរមានទំហំប៉ុនណាសម្រាប់ការជ្រើសរើសនេះ?

- រូបថតគួរអាចជារូបស្កេនពីហ្វីលដើម ត្រូវមានខ្នាតបណ្តោយ១៥០០ ភិចសែល និងជាប្រភេទរូប jpeg (ទំហំប្រហែល១ មេហ្គាបៃ)។

ដើម្បីផ្តិតរូប តើខ្ញុំត្រូវផ្ញើឯកសារស្កេនដែរឬទេ?

ទេ! យើងនឹងស្កេនរូបនោះសាជាថ្មីក្នុងកម្រិតគុណភាពខ្ពស់។ ការផ្តិតនេះនឹងធ្វើឡើងដោយស្ទូឌីយោ RUUB។ ដើម្បីធ្វើឱ្យគុណភាពរូបមានទម្រង់តែមួយ យើងនឹងមិនអនុញ្ញាតឱ្យអ្នកថតរូបផ្តល់ឯកសារស្កេន ឬផ្តិតរូបដោយខ្លួនឯងសម្រាប់ការតាំងពិព័ណ៌នេះឡើយ។ សូមអរគុណចំពោះការយោគយល់របស់អ្នកទាំងអស់គ្នា!

បន្ទាប់ពីពិព័រណ៍ចប់រួចរាល់ តើរូបថតទាំងអស់នេះនឹងទៅណា?

- រូបថតទាំងអស់នេះនឹងក្លាយជារបស់អ្នក! អ្នកអាចរក្សាទុកវាបាន។

តើការចូលរួមមានការគិតថ្លៃដែរឬទេ?

- មិនមានការគិតថ្លៃសម្រាប់ការបញ្ជូនឯកសាររូបថតមកចូលរួមទេ ប៉ុន្តែអ្នកថតរូបជាប់ជម្រើសត្រូវបង់ថ្លៃលើការស្កេន និងការផ្តិតចេញជារូប។
  - ស្កេន ៖ តម្លៃក្នុងហ្វីលមួយសន្លឹក ៦ដុល្លារ / ៣៥មម ឬ៦.៥ដុល្លារ ទំហំមធ្យម (ធំជាង ៦x ៧)
  - ផ្តិតរូបថតដោយ៖ ស្ទូឌីយោ RUUB៖ ទំហំ A4 តម្លៃ១០ ដុល្លារ ក្នុងមួយសន្លឹក x ២ = ២០ ដុល្លារ

តើខ្ញុំអាចបញ្ជូនរូបថតលើសពីមួយបានទេ?

- ប្រាកដណាស់! បេក្ខជនម្នាក់អាចបញ្ជូនរូបហូតដល់១០ សន្លឹក។

តើធ្វើម៉េចទើបខ្ញុំដឹងថា រូបរបស់ខ្ញុំត្រូវបានជ្រើសរើស?

- យើងនឹងទាក់ទងទៅអ្នកនៅថ្ងៃទី១០ ខែកញ្ញា ហើយប្រកាសទៅសាធារណជននៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣។ សូមប្រាកដថា ក្នុងការដាក់ពាក្យរបស់អ្នក អ្នកបានផ្តល់អ៊ីមែល និងលេខទូរស័ព្ទត្រឹមត្រូវ!

**លក្ខខណ្ឌ**

តាមរយៈការចូលរួមនៅក្នុងការប្រកួតរូបថតនេះ អ្នកព្រមព្រៀងថា អ្នកគឺជាម្ចាស់រូប ឬជាអ្នកមានកម្មសិទ្ធិលើរូបថតដែលបានបញ្ជូនមក ឬក៏អ្នកមានសិទ្ធិពីអ្នកថតរូប (ឬពីក្រុមគ្រួសាររបស់ពួកគេ)។ អ្នកធានាថា រូបបុគ្គលម្នាក់ៗដែលបានបង្ហាញតាមរយៈរូបថតនេះបានព្រមព្រៀងសម្រាប់ការតាំងបង្ហាញជាសាធារណៈ។

អ្នករូបថតតែងតែរក្សាកម្មសិទ្ធិលើរូបថតរបស់ពួកគេជានិច្ច។ អ្នករៀបចំកម្មវិធីពិព័រណ៍ (ហាងកាហ្វេចាវ៉ា ស្ទូឌីយ៉ូ RUUB) មានសិទ្ធិដើម្បីប្រើប្រាស់រូបថតដែលអ្នកបានបញ្ជូនមកសម្រាប់ការផ្សព្វផ្សាយ និងសកម្មភាពផ្សព្វផ្សាយនានាដែលទាក់ទងទៅនឹងការតាំងពិព័រណ៍ ដោយគ្មានការបង់ប្រាក់។ សកម្មភាពទាំងអស់នេះរួមមានការផ្សព្វផ្សាយតាមបណ្តាញសង្គម វេបសាយ ការបោះពុម្ពផ្សាយ ពិព័រណ៍នានា និងការបញ្ចាំងជាសាធារណៈផ្សេងៗ។ ចំពោះការផ្សព្វផ្សាយបែបនេះ អ្នកថតរូបនឹងទទួលបានក្រេឌីតជានិច្ច។

ការប្រើប្រាស់រូបថតដោយអ្នករៀបចំកម្មវិធីពិព័រណ៍ គឺក្នុងទម្រង់មិនផ្តាច់មុខ និងមិនបង្កើតប្រាក់ចំណេញឡើយ។ នេះមានន័យថា អ្នកចូលរួមអាចបន្តប្រើប្រាស់រូបថតទាំងអស់នេះ ហើយអ្នករៀបចំកម្មវិធីមិនមានគោលបំណងបង្កើតប្រាក់ចំណេញជាមួយនឹងរូបថតដែលបានបញ្ជូនមកកម្មវិធីនេះឡើយ។ សូមបញ្ជាក់ថា ប្រសិនបើ

ការដាក់ពាក្យរបស់អ្នកត្រូវបានជ្រើសរើស រូបថតរបស់អ្នកនឹងត្រូវផ្សព្វផ្សាយតាមរយៈអនឡាញ និងផ្ដិតជារូប ក្នុងគោលបំណងដើម្បីការតាំងពិព័រណ៍សាធារណៈផងដែរ។

ប្រសិនបើត្រូវបានជ្រើសរើស អ្នកចូលរួមត្រូវផ្ដល់សន្លឹកហ្វីលដើម ដើម្បីស្កេនជាថ្មីក្នុងកម្រិតគុណភាពខ្ពស់។ បន្ថែមពីនេះ ការដាក់ពាក្យមកកាន់កម្មវិធី គឺមានន័យថាអ្នកចូលរួមម្នាក់ៗបានអនុញ្ញាតឱ្យអ្នករៀបចំកម្មវិធី ពិព័រណ៍ (ហាងកាហ្វេចាវ៉ា និងស្ទូឌីយ៉ូ RUUB) មានសិទ្ធិគ្រប់គ្រាន់ដើម្បីប្រើប្រាស់រាល់សេចក្ដីដែលអ្នកមាន ពាក់ព័ន្ធនឹងរូបថតប្រកួត និងកម្មវិធីតាំងពិព័រណ៍ ក៏ដូចជាសិទ្ធិក្នុងការប្រើប្រាស់រូបថត ឬភាពពេញចិត្តរបស់ អ្នកចូលរួមទៅតាមការវិនិច្ឆ័យរបស់អ្នករៀបចំកម្មវិធី។

Java